
www.kidsofdestiny.org
Kids of Destiny®
Reaching the Next Generation

## 4.06 អ្នកសំលាប់យក្ស

### ១សាំយូអែល ១៧

“ដាវិឌជាក្មេងប្រុសម្នាក់ដែលបានមើលថែរក្សាកសិដ្ឋានចិញ្ចឹមសត្វរបស់ឪពុកគាត់ហើយគាត់ស្រឡាញ់ព្រះអម្ចាស់ខ្លាំងណាស់។ ព្រះទ្រង់បានប្រទានឲ្យគាត់នូវអំណាច ដើម្បីធ្វើកិច្ចការដែលមនុស្សគិតថា មិនអាចធ្វើបាន។ ដាវិឌមានបងប្អូនប្រុស ៧នាក់ ដែលកំពុងប្រយុទ្ធធ្វើសង្គ្រាមនៅឆ្ងាយប្រឆាំងនឹងសត្រូវឈ្លានពានប្រទេស។ ឪពុកដាវីឌបានឲ្យគាត់យកអាហារឆ្ងាញ់ៗ ទៅឲ្យបងប្រុសរបស់គាត់។ នៅពេលទៅដល់បន្ទាយទាហាន ដើម្បីសួរសុខទុក្ខបងប្រុសគាត់។ គាត់សង្កេតឃើញថាគ្មាននរណាម្នាក់ប្រយុទ្ធគ្នាទេពួកគេកំពុងអង្គុយជុំវិញគ្នាមើលទៅដូចជាភ័យខ្លាំងណាស់។បុរសដែលគួឲ្យខ្លាចម្នាក់បានស្រែកពីលើភ្នំមក។ “បញ្ជូនអ្នកក្លាហាន និងខ្លាំងជាងគេរបស់ឯងមក ដើម្បីប្រយុទ្ធនឹងយើង" បុរសដែលស្រែកនោះឈ្មោះកូលីយ៉ាត។ បើសិនជាទាហានដែលខ្លាំងពូកែរបស់ឯងឈ្នះយើង នោះកងទ័ពរបស់យើងនឹងធ្វើជាទាសកររបស់ពួកឯង។

ប៉ុន្តែបើយើងឈ្នះការប្រយុទ្ធពួកឯងទាំងអស់គ្នា នឹងក្លាយជាទាសកររបស់យើងវិញ “កូលីយ៉ាតបានស្រែកអះអាង"។ ដាវិតបានឮយក្ស ហើយបានឃើញអ្នកទាំងអស់គ្នាភ័យខ្លាំងណាស់។ ទាហានទាំងអស់មានការភិតភ័យចំពោះកងទ័ពរបស់សត្រូវ ជាមួយនឹងកូលីយ៉ាតនៅម្ខាងទៀតណាស់! នៅពេលគ្មានទាហានរបស់ស្តេចសូលណាម្នាក់បានស្ម័គ្រចិត្ត ដាវិឌបានសម្រេចចិត្តប្រយុទ្ធជាមួយយក្ស។ ស្តេចសូលបានជួបដាវីឌហើយព្យាយាមដាស់តឿនថា ប្រយុទ្ធជាមួយយក្សគឺគ្រោះថ្នាក់ណាស់។ ស្តេចសូល បានឲ្យអាវក្រោះការពារផ្ទាល់ខ្លួនរបស់ទ្រង់សម្រាប់ដាវីឌដើម្បីពាក់ប្រយុទ្ធ ។

ដាវិឌមានអារម្មណ៍ក្លាហាន ដែលព្រះគង់នៅជាមួយគាត់ ដូច្នេះគាត់មិនពាក់អាវក្រោះរបស់ស្តេចសូលទេ ម្យ៉ាងទៀតអាវនោះធំណាស់ មិនល្មមនឹងរាង្គកាយដ៏តូចរបស់គាត់ឡើយ។ ដាវីឌបានចេញទៅក្រៅជំរំ ដើម្បីជួបកូលីយ៉ាត ហើយយក្សធំនោះបានស្រែកទាំងសើចចំអក ។ ដាវីឌ គឺមិនមានការភ័យខ្លាចទេ ហើយគាត់បានរកមើលដុំថ្មរលោងៗ ប្រាំគ្រាប់នៅលើដីក្បែរស្ទឹងដាក់ក្នុងថង់យាមរបស់គាត់។ “ឯងគ្រាន់តែជាក្មេងប្រុសម្នាក់ ឯងមិនអាចយកឈ្នះយើងបានទេ!" កូលីយ៉ាតនៅតែសើចចំអក។ ដាវីឌ មានអារម្មណ៍ថា ព្រះអម្ចាស់ធ្វើឲ្យគាត់មានភាពក្លាហានយ៉ាងខ្លាំង នៅក្នុងជំនឿរបស់គាត់ ហើយគាត់ក៏ស្រែកទៅកូលីយ៉ាតវិញថា “ឯងមកប្រយុទ្ធនឹងខ្ញុំជាមួយដាវមួយនិងលំពែងមួយ។

ប៉ុន្តែយើងមកប្រយុទ្ធជាមយួយនឹងឯងដោយនូវព្រះនាមព្រះអម្ចាស់ ដែលជាអ្នកត្រួតត្រាលើគ្រប់ទាំងអស់។ ទ្រង់គឺជាស្តេចនៃកងទ័ពអ៊ីស្រាអែល។ ទ្រង់គឺជាម្នាក់ដែលអ្នកបានហ៊ានប្រយុទ្ធតតាំង។ ដាវីឌបានដកដុំថ្មយ៉ាងរលោងមួយគ្រាប់ ពីក្នុងថង់យាមរបស់គាត់មក ហើយដាក់វានៅក្នុងថ្នក់ខ្សែដង្ហក់របស់គាត់។ វាហៅខ្សែដង្ហក់ ព្រោះមនុស្សម្នាក់ ដែលពោរពេញដោយជំនាញអាចគ្រវែងបានក្នុងល្បឿនយ៉ាងអស្ចារ្យ និងពោរពេញដោយថាមពល។ វាគឺជាខ្សែដង្ហក់តែមួយដែលគាត់បានប្រើប្រាស់ដើម្បីប្រយុទ្ធនឹងសត្វព្រៃដែលចង់ចង់ចាប់សត្វចៀមរបស់គាត់ នៅពេលដែលគាត់ធ្វើជាអ្នកគង្វាលចៀមនៅឯស្រែ។ ដាវីឌបានចោលទៅលើមេឃ ហើយដុំថ្មបានហោះតម្រង់ចំថ្ងាសរបស់កូលីយ៉ាត។ យក្សបានដួលទៅលើដី ហើយដាវិឌក៏បានឈ្នះការប្រកួត ។

**រ៉ូម ១០:១៣**" ហើយគ្រប់គ្នាគឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់នោះនឹងបានសង្គ្រោះ" ។

4.06 **អ្នកសំលាប់យក្ស - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន**
**កំណាត់សំគាល់**:

១. ដាវីឌគឺជាក្មេងប្រុសម្នាក់ ដែលស្រឡាញ់ព្រះអម្ចាស់ខ្លាំងណាស់។ ព្រះអម្ចាស់បានផ្តល់អំណាចដល់ដាវីឌ គាត់អាចធ្វើរឿងដែលមនុស្សធម្មតាធ្វើមិនបាន ។
២. បងប្រុសរបស់ដាវីឌកំពុងធ្វើសឹកច្បាំងនឹងសត្រូវ ។ មានសត្រូវម្នាក់ជាយក្សឈ្មោះកូលីយ៉ាត ។ កូលីយ៉ាតបាននិយាយថាគាត់ចង់ប្រយុទ្ធ បើគាត់ឈ្នះគ្រប់គ្នាត្រូវតែធ្វើជាទាសកររបស់គាត់ ។
៣. ដាវីឌប្រាប់ស្តេចសូលថា គាត់ចង់ប្រយុទ្ធជាមួយកូលីយ៉ាត។ ស្តេចសូលចង់ឲ្យដាវីឌពាក់គ្រឿងសឹកដ៏ពិសេសរបស់ទ្រង់ប៉ុន្តែដាវីឌបាននិយាយថា ព្រះអម្ចាស់គង់នៅជាមួយគាត់ គាត់មិនត្រូវការគ្រឿងសឹករបស់ស្តេចឡើយ ។
៤. ដាវីឌចេញទៅជួបកូលីយ៉ាត ។ កូលីយ៉ាតចំអកឲ្យដាវីឌ ឯងគ្រាន់តែជាក្មេងម្នាក់ប៉ុណ្ណោះ ឯងមិនអាចយកឈ្នះយើងបានទេ ។ ដាវីឌតបថា គាត់មកប្រយុទ្ធក្នុងនាមព្រះអម្ចាស់ គឺជាព្រះនៃទ័ពទាហានរបស់អ៊ីស្រាអែល។
៥. ដាវីឌបានប្រើថ្មរលោងពីកាបូបគាត់ដាក់ចូលក្នុងខ្សែដង្ហក់។ គាត់បានគ្រវែងខ្សែដង្ហក់ហើយដុំថ្មហោះត្រង់ទៅរកថ្ងាស់របស់កូលីយ៉ាត ។ ដាវីឌបានឈ្នះសង្គ្រាម។

**សំណួរ**

១) តើរឿងនេះនិយាយពីនរណា?
២) តើដាវីឌបានកំលាំងពិសេសនេះមកពីណា?
៣) តើយក្សដែលចង់ច្បាំងនោះ ឈ្មោះអ្វី?
៤) តើដាវីឌត្រូវការគ្រឿងសឹករបស់ស្តេចសូល ឬទេ?
៥) តើដាវីឌនិយាយអ្វីទៅកូឡីយ៉ាត?
៦) តើដាវីឌធ្វើដូចម្តេចទើបឈ្នះសង្គ្រាម?

**ចម្លើយ**

១) រឿងនេះនិយាយអំពីកុមារដេវីឌ ដែលស្រឡាញ់ព្រះ ។
២) ព្រះទ្រង់បានប្រទានឲ្យដាវីឌមានកម្លាំងពិសេស ។
៣) យក្សមានឈ្មោះថា កូលីយ៉ាត ។
៤) ដាវីឌមិនត្រូវការគ្រឿងសឹករបស់ស្តេចសូលទេ ដាវីឌដឹងថាព្រះអម្ចាស់នៅខាងគាត់ ។
5) ដាវីឌបានប្រាប់កូលីយ៉ាតថា យើងមកក្នុងនាមរបស់ព្រះអម្ចាស់ ។
៦) ដាវីឌដាក់ថ្មក្នុងខ្សែដង្ហក់ ហើយគ្រវែងថ្មនោះចំថ្ងាស់របស់កូលីយ៉ាត ។

Kids of Destiny
Reaching the Next Generation

